ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អគ្គនាយកដ្ឋានពន្ធដារ
នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ៧០១១ អពដ

រាជធានីភ្នំពេញ, ថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១៣

សេចក្តីជូនដំណឹង
ស្តីពី
វគ្គបណ្តុះបណ្តាលមុខវិជ្ជាពន្ធដារ

អគ្គនាយកដ្ឋានពន្ធដារ មានកិត្តិយសសូមជម្រាបជូនដល់ លោក លោកស្រីជាបណ្ណាធិការ នាយក ប្រធាន និងអ្នកគ្រប់គ្រងក្រុមហ៊ុន សហគ្រាស សមាគម អ្នកជាប់ពន្ធ បុគ្គលិកក្រុមហ៊ុន សិស្ស និស្សិត និងសាធារណជនទាំងអស់ មេត្តាជ្រាបថា សាលាជាតិពន្ធដារ នៃអគ្គនាយកដ្ឋានពន្ធដារ បាន រៀបចំវគ្គបណ្តុះបណ្តាលមុខវិជ្ជាពន្ធដារ ដែលនឹងចាប់ផ្តើមចូលរៀនដំបូងនៅថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៣ ខាងមុខនេះ ដែលមាន ០៤ វេន សម្រាប់ជ្រើសរើស មានដូចជា៖

-ពេលព្រឹក (ថ្ងៃច័ន្ទ ដល់ ថ្ងៃសុក្រ) ៖ ម៉ោង ៨.00 - ១១.00
-ពេលរសៀល(ថ្ងៃច័ន្ទ ដល់ ថ្ងៃសុក្រ) ៖ ម៉ោង ១៤.00 - ១៧.00
-ពេលយប់(ថ្ងៃច័ន្ទ ដល់ ថ្ងៃសុក្រ) ៖ ម៉ោង ១៧.៣០ - ២០.៣០
-ពេលចុងសប្តាហ៍ (ថ្ងៃសៅរ៍ - ថ្ងៃអាទិត្យ)៖ ម៉ោង ០៨.00- ១១.00 និង
ម៉ោង ១៤.00 - ១៧.00

អាស្រ័យហេតុនេះ សូមអស់លោក លោកស្រី នាងកញ្ញា ដែលមានបំណងចង់សិក្សាមុខវិជ្ជាពន្ធដារនេះ និងចង់ស្វែងយល់សំរាប់ការងារវិជ្ជាជីវៈរបស់ខ្លួន ឬចង់ក្លាយជាភ្នាក់ងារសេវាកម្មពន្ធដារ សូមអញ្ជើញមកទំនាក់ទំនង ដើម្បីសាកសួរព័ត៌មានលម្អិត និងចុះឈ្មោះសិក្សាចាប់ពីថ្ងៃជូនដំណឹងនេះតទៅ នៅសាលាជាតិពន្ធដារ នៃអគ្គនាយកដ្ឋានពន្ធដារ ដែលមានអាស័យដ្ឋាន៖ អគារលេខ ៤១-៤៣ ផ្លូវលេខ ១១២ សង្កាត់ផ្សារដេប៉ូ៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ (ខាងកើតអគារអគ្គនាយកដ្ឋានពន្ធដារ)។

ទូរស័ព្ទលេខ៖០២៣ ៨៨១ ៩៦០ , ០៨៨ ៩៧៩ ៣៣៦៦

Email ÷nts@tax.gov.kh

អគ្គនាយកដ្ឋានពន្ធដារ